# គណបក្ស សម រង្ស៊ី

**SAM RAINSY PARTY**
**PARTI SAM RAINSY**
**សីលធម៌ សច្ចធម៌ យុត្តិធម៌**

# សេចក្តីអំពាវនាវ

គណបក្ស សម រង្ស៊ី សូមជំរាបជូនដំណឹងដល់សមាជិក-សមាជិកាគណបក្ស សម រង្ស៊ី និងសប្បុរសជននៅឯនាយសមុទ្រឲ្យបានជ្រាបថា លោក **គង់ ទៀន** អាយុ៤២ឆ្នាំ សកម្មជនគណបក្ស សម រង្ស៊ី នៅភូមិត្រពាំងធ្លក ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ត្រូវឃាតកបាញ់សម្លាប់នៅវេលាម៉ោង២០យប់ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៤ ។

លោក **គង់ ទៀន** ត្រូវឃាតកមិនស្គាល់មុខប្រដាប់ដោយអាវុធអាកា៤៧ បាញ់ពីក្រោយខ្នង បណ្តាលឲ្យស្លាប់ភ្លាមនៅហ្នឹងកន្លែង ខណៈពេលដែលលោកកំពុងជួបជុំក្រុមគ្រួសារ និងមិត្តភក្តិនៅផ្ទះបងប្អូនជីដូនមួយរបស់លោកនៅភូមិត្រពាំងធ្លក ។

លោក **គង់ ទៀន** គឺជាសមាជិកសកម្មនៃក្រុមប្រឹក្សាគណបក្ស សម រង្ស៊ី ភូមិត្រពាំងធ្លក ។ មរណភាពរបស់លោក **គង់ ទៀន** បានបន្សល់ទុកនូវភរិយាមេម៉ាយឈ្មោះ **អ៊ិក រី** អាយុ៣២ឆ្នាំ និងកូន៦នាក់ក្នុងបន្ទុក ។

ដើម្បីជួយសំរាលទុក្ខសោកដល់គ្រួសារសពលោក **គង់ ទៀន** និងតាងនាមក្រុមគ្រួសារជនរងគ្រោះ និងតាងនាមគណបក្ស សម រង្ស៊ី ខ្ញុំសូមអំពាវនាវដល់សមាជិក-សមាជិកាគណបក្ស និងសប្បុរសជននៅឯនាយសមុទ្រមេត្តាជួយតាមលទ្ធភាព និងសមានចិត្ត ដល់គ្រួសារសពលោក **គង់ ទៀន** ដែលទទួលរងគ្រោះដោយអំពើឃាតកម្មនេះ ។

ខ្ញុំសូមថ្លែងអំណរគុណទុកជាមុនដល់សមាជិក-សមាជិកាគណបក្ស និងបងប្អូនជនរួមជាតិនៅឯនាយសមុទ្រដែលបានជួយផ្តល់ជាវិភាគទានដើម្បីសំរាលទុក្ខក្រុមគ្រួសារសពលោក **គង់ ទៀន** ហើយនិងសូមជូនពរឲ្យជួបប្រទះនូវពុទ្ធពរទាំងប្រាំប្រការ គឺ : អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ៕

*រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៤*

**អគ្គលេខាធិការគណបក្ស**

**អេង ឆៃអ៊ាង**

ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphqpp@forum.org.kh, cabinet@samrainsyparty.org